# ការជ្រើសវ៉ាក់សាំងកូវីដ-19 ដែលត្រឹមត្រូវសម្រាប់អ្នក

**វ៉ាក់សាំងកូវីដ-19 គឺមានជូននៅក្នុងសហរដ្ឋអាមេរិក ។ សូមយល់ អំពីអត្ថប្រយោជន៍និងហានិភ័យដើម្បីជួយអ្នកឲ្យសម្រេចចិត្តថា តើវ៉ាក់សាំងណាមួយត្រឹមត្រូវសម្រាប់អ្នក ។**




## កូវីដ-19 អាចធ្វើឲ្យមានជម្ងឺធ្ងន់ធ្ងរ

កូវីដ-19 ត្រូវបានបណ្ដាលដោយវីរុសកូរ៉ូណា ដែលរាលដាលតាមរយៈខ្យល់ ជាពិសេសនៅពេលបុគ្គលដែលមានការចម្លង និយាយកដាស ឬ ក្អកក្នុងអគារ កូវីដ-19 អាចបណ្ដាល់ឲ្យមានការឈឺធ្ងន់ធ្ងរ គ្រុនរលាកសួតនឹងមរណភាព ហើយយើងនៅតែរៀនអំពីការប៉ះពាល់ កំឡុងពេលយូរ ។

## ការវាក់វ៉ាក់សាំងគឺត្រូវបានណែនាំសម្រាប់បុគ្គលអាយុ 21 និងចាស់ជាង

មជ្ឈមណ្ឌលគ្រប់គ្រប់ជម្ងឺនិងការពារ (center of disease and control, cdc) គឺត្រូវបានណែនាំសម្រាប់បុគ្គលគ្រប់រូបដែលមានអាយុ 12 និងចាស់ជាងទទួលការចាក់វ៉ាក់សាំង កូវីដ-19 ។ វាគឺជាជម្រើសរបស់អ្នកដើម្បីទទួលវ៉ាក់សាំង ។

## ជម្រើសវ៉ាក់សាំង

Pfizer-BioNTech (2 ដូស ចន្លោះពេល 21 ថ្ងៃ), ក៏មានឈ្មោះ Comirnaty ដែលត្រូវបានអនុម័តដោយ រដ្ឋបាលអាហារនិងឱសថ (Food and Drug Administration, FDA) សម្រាប់បុគ្គលអាយុ 16 និងចាស់ជាង ។ វ៉ាក់សាំង Pfizer-BioNTech មានការអនុញ្ញាតប្រើប្រាស់ជាបន្ទាន់របស់FDA សម្រាប់ការប្រើប្រាស់សម្រាប់បុគ្គលអាយុ 12 ដល់ 15 ឆ្នាំ ។ Moderna (2 ដូស ក្នុងចម្លោះ 28 ថ្ងៃ) និងវ៉ាក់សាំង Johnson & Johnson (1 ដូស) មានការអនុញ្ញាត ប្រើប្រាស់ ជាបន្ទាន់ របស់ FDA សម្រាប់បុគ្គលអាយុ 18 ឆ្នាំ និងចាស់ជាង ។

## អត្ថប្រយោជន៍ នៃការទទួលវ៉ាក់សាំងកូវីដ

វ៉ាក់សាំងទាំងអស់ មានជូនសម្រាប់អ្នក ៖

- **ត្រូវបានអនុម័តថាមានសុវត្ថិភាពនិងប្រសិទ្ធិភាពចំពោះការការពារ កូវីដ-19**
- **ជួយការពារបុគ្គលពីការឈឺ ជម្ងឺធ្ងន់ធ្ងរ ឬមរនាភាពពីកូវីដ-19**
- **ជួយការពារបុគ្គលពីការចម្លងវីរុសទៅអ្នកដទៃទៀត**

ដើម្បី ទទួលការការពារភាគច្រើន បំផុត បុគ្គលត្រូវតែទទួលដូសនៃវ៉ាក់សាំង ដែលត្រូវបានណែនាំ ។ ការចាក់ថ្នាំមនុស្សកាន់តែច្រើនកាន់តែល្អ នឹងជួយយើងគ្រប់រូបឆ្លងផុតពីរោគរីករាលដាល ។

## អ្វីដែលគួរតែរំពឹងទុកជាមុននៅពេលអ្នកទទួលវ៉ាក់សាំង

**ផលប៉ះពាល់ទូទៅ** (វ៉ាក់សាំង-19 ទាំងអស់) ៖ ពីរបីថ្ងៃ ក្រោយពីការចាក់វ៉ាក់សាំង អ្នកអាចមានការឈឺចាប់ឬការហើមនៅត្រង់កន្លែងចាក់ថ្នាំ ឬការឈឺក្បាល ការហត់ការឈឺសាច់ដុំ ការចង់ក្អួតឬការគ្រុន។សញ្ញាជម្ងតាទាំងនេះដែលខ្លួនប្រាណរបស់អ្នកកំពុងតែស្ថាបនាការការពារ។

CDPH California Department of Public Health

 © 2021, California Department of Public Health




## ហានិភ័យទាក់ទងជាមួយការទទួលវ៉ាក់សាំង

- **ប្រតិកម្មធ្ងន់ធ្ងរកម្រមាន** (វ៉ាក់សាំង-19 ទាំងអស់) ៖ កម្រមានប្រតិកម្មអាលែហ្ស៊ីភ្លាមៗអាចកើតឡើងក្នុងរយៈពេលពីរបីនាទីទៅមួយម៉ោង បន្ទាប់ពីទទួលថ្នាំរួមទាំងកន្ទួលរមាស់ ឬកន្ទួលរមាស់ពិបាកដកដង្ហើម ឬលេបហើមមុខឬបំពង់ក វិលមុខឈឺក្រពះឬជីពចរលឿន ។
- **កំណកឈាមកម្រមាន** (J&J) ៖ បុគ្គលមួយចំនួនតូចបានអភិវឌ្ឍន៍កំណកឈាមដែលកម្រមានក្នុងកំឡុងពីរបីសប្តាហ៍ដំបូងក្រោយពីការចាក់ការចាក់វ៉ាក់សាំង Johnson & Johnson ។ មានកំណកឈាម នៃសរសៃឈាមក្នុងខួរក្បាល ពោះ ឬ ជើងតាមកម្រិតឈាមទាបនៃកោសិកាដែលបញ្ឈប់ការចេញឈាម និងអាចបង្កើតនូវជម្ងឺធ្ងន់ធ្ងរ ឬសេចក្តីស្លាប់ ។ មនុស្សភាគច្រើនដែលបានអភិវឌ្ឍន៍កំណកឈាមទាំងនេះ គឺជាស្ត្រីមានអាយុក្រោម50 ឆ្នាំ ។ រោគសញ្ញារបស់ពួកគេបានចាប់ផ្តើម 1–2 សប្តាហក្រោយពីការចាក់វ៉ាក់សាំង ។ រហូតដល់ពេលនេះ កំណកឈាមកម្រមានទាំងនេះ មិនត្រូវបានជាប់ទាក់ទងនឹងវ៉ាក់សាំង Pfizer or Moderna ។
- **ជំងឺរលាកសាច់ដុំបេះដូងនិងរលាកស្រោមបេះដូងកម្រមាន** (Pfizer-BioNTech and Moderna) ៖ មានករណីកម្រនៃជំងឺរលាកសាច់ដុំបេះដូងនិងរលាកស្រោមបេះដូងបន្ទាប់ពីការចាក់វ៉ាក់សាំង កូវីដ-19 mRNA (Pfizer-BioNTech និង Moderna) ជាពិសេសចំពោះក្មេងជំទង់ប្រុសនិងមនុស្សចាស់ជាញឹកញាប់បន្ទាប់ពីទទួលបានថ្នាំលើកទី 2 ច្រើនជាងកម្រិតដំបូងហើយជាធម្មតាក្នុងរយៈពេលប៉ុន្មានថ្ងៃនៃការចាក់វ៉ាក់សាំង ។ រោគសញ្ញារួមមានការឈឺទ្រូងការដកដង្ហើមខ្លី ការមានអារម្មណ៍ថាមានបេះដូងលោតខ្លាំងដើរលឿនឬលោតញាប់ ។
- **រោគ Rare Guillain-Barre Syndrome** (J&J) ៖ មានករណីកម្រមាននៃជម្ងឺ Guillain-Barre Syndrome ក្រោយពីការទទួលវ៉ាក់សាំង កូវីដ-19 Johnson & Johnson ។ ជម្ងឺ Guillain-Barre Syndrome គឺជាជំងឺសរសៃប្រសាទដែលប្រព័ន្ធការពាររាងកាយបំផ្លាញកោសិកាសរសៃប្រសាទបណ្តាលឲ្យសាច់ដុំចុះខ្សោយឬក្នុងករណីធ្ងន់ធ្ងរបំផុតគឺការខ្វិន។ ករណី Guillain-Barre Syndromeភាគច្រើនត្រូវបានរាយការណ៍ ថាប្រហែលជា2 សប្តាហក្រោយពីការចាក់វ៉ាក់សាំង-19Johnson & Johnson ហើយភាគច្រើនក្នុងបុរស អាយុ 50 ឆ្នាំនិងចាស់ជាង ។ អ្នកត្រូវតែស្វែងរកការព្យាបាល វេជ្ជសាស្ត្រ ប្រសិនបើអ្នកមានការអស់កម្លាំងការព្រឺស្រាញ ក្នុងជើងទាំងពីរ ដែលអាចរាលដាលដល់ដៃនិងពាក់កណ្តាលខ្លួនខាងលើ ។

## ស្វែងរកការថែទាំ

ស្វែងរកការព្យាបាលខាងវេជ្ជសាស្ត្រ ជាបន្ទាន់ឬហៅទៅលេខ 9-1-1 ប្រសិនបើអ្នកមានរោគសញ្ញាធ្ងន់ធ្ងរបន្ទាប់ពីចាក់វ៉ាក់សាំងដូចជាពិបាកដកដង្ហើម ឬការលេបការហើមមុខឬបំពង់ក ពិបាកដកដង្ហើមឈឺទ្រូងហើមជើងឈឺពោះជាប់រហូត  ការឈឺក្បាលធ្ងន់ធ្ងរការមានចក្ខុវិស័យព្រិលស្នាមជាំជាច្រើនឬស្នាមឈាមតូចៗនៅក្រោមស្បែករបស់អ្នក ។ ទូរស័ព្ទទៅអ្នកផ្តល់ការចាក់វ៉ាក់សាំងឬអ្នកផ្តល់ការថែទាំសុខភាពប្រសិនបើអ្នកមានរោគសញ្ញាដែលរំខានដល់អ្នកឬមិនបាត់វិញក្រោយពីពីរបីថ្ងៃ ។

## ព័ត៌មានបន្ថែម

ប្រសិនបើអ្នកត្រូវការជំនួយធ្វើការណាត់ជួបឬ មានសំណួរ សូមទូរស័ព្ទ លេខ (833) 422-4255 ឬចូលទៅ VaccinateAll58  ឬ គេហទំព័រ CDPH